- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១ :** ត្រូវបានផ្ទេរឥណទាន ពីជំពូក៣១ (អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌) ចំនួន៣.៧២៤លានរៀល (បីពាន់ប្រាំពីររយម្ភៃបួនលានរៀលគត់) មកជំពូក៣២ (អន្តរាគមន៍ ក្នុងវិស័យអន្តរជាតិ) ក្នុងថវិការបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៦ ។

**មាត្រា ២ :** ឥណទានក្នុងមាត្រា១ ត្រូវបានអនុញ្ញាតអោយប្រើប្រាស់ ដើម្បីចាត់វិធានការផ្នែក ហិរញ្ញវត្ថុ អោយបានទាន់ពេលវេលាសំរាប់ប្រទេសកម្ពុជា ដែលត្រូវជាសមាជិក អាស៊ាន ក្នុងឆ្នាំ ១៩៩៧ ខាងមុខនេះ ។

**មាត្រា ៣ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថ - លេខានេះតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៩៩៧

## អនុក្រឹត្យលេខ : ១៨ អនក្រ.បក

## ស្តីពី

## អាហារូបករណ៍ និង របបឧបត្ថម្ភជីវភាពអន្តេវាសិក

* * *

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស-៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស-រកម-០១៩៦-០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការ បង្កើតក្រសួងអប់រំយុវជននិងកីឡា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា

**សំរេច**

មាត្រា ១ : អាហារូបករណ៍ប្រចាំខែរបស់សិស្សនិងនិស្សិត ដែលបានបណ្តុះបណ្តាលនៅតាមគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់តាមកំរិតដូចមានខាងក្រោម ÷

- ក្រោមឧត្តមសិក្សា : ១២.០០០៛
- ឧត្តមសិក្សា : ១០.០០០៛
- មធ្យមសិក្សាឯកទេស : ៩.០០០៛
- បឋមសិក្សាឯកទេស : ៨.០០០៛

របបឧបត្ថម្ភអន្តេវាសិកនេះ ត្រូវអនុវត្តចាប់តាំងពីខែមីនា ឆ្នាំ១៩៩៧ នេះតទៅ ។

មាត្រា ២ : ការផ្តល់អាហារូបករណ៍ប្រចាំខែត្រូវអនុវត្តតែក្នុងរយៈពេលកំពុងសិក្សា ។ ពេលឈប់សំរាកក្នុងឱកាសមហាវិស្សមកាល និងពេលព្យួរការសិក្សា សិស្ស និស្សិត មិនត្រូវបានទទួលប្រាក់អាហារូបករណ៍ឡើយ ។

ក្នុងករណីសិស្ស និស្សិតរៀនធ្លាក់ថ្នាក់ រដ្ឋនឹងផ្តាច់អាហារូបករណ៍វិញលើកលែងតែសិស្ស និស្សិត ដែលស្ម័គ្រចិត្តធ្វើគ្រូ ត្រូវអនុវត្តតាមបទបញ្ជាផ្ទៃក្នុងរបស់គ្រឹះស្ថានសិក្សានោះ ។

**មាត្រា ៣** : ចំនួនសិស្ស និស្សិត ដែលត្រូវទទួលអាហារូបករណ៍ ត្រូវកំណត់ដូចតទៅ ÷

ក– នៅតាមគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស :

– កំរិតក្រោយឧត្តមសិក្សា : ៥០ ភាគរយ

– កំរិតឧត្តមសិក្សា : ១០ ភាគរយ

– កំរិតមធ្យមសិក្សាឯកទេស : ៤០ ភាគរយ

– កំរិតបឋមសិក្សាឯកទេស : ៣៥ ភាគរយ

– និស្សិតកំរិតក្រោយឧត្តមសិក្សា និងឧត្តមសិក្សា ការកំណត់អត្រាអាហារូបករណ៍ ៥០ភាគរយ និង ១០ភាគរយ នឹងត្រូវអនុវត្តពីឆ្នាំសិក្សា១៩៧៩–៩៨ តទៅ ចំពោះនិស្សិតដែលទើបប្រលងជាប់ ថ្មី។

–និស្សិតក្រោយឧត្តមសិក្សា និងឧត្តមសិក្សា ដែលកំពុងសិក្សានៅតាមគ្រឹះស្ថានសិក្សានានា ត្រូវបានទទួលអាហារូបករណ៍ប្រចាំខែ តាមកំរិតដូចក្នុងមាត្រា១ តាមអត្រាភាគរយចាស់ គឺ ១០០ភាគរយ និង៣០ភាគរយ រហូតដល់បញ្ចប់ការសិក្សារបស់ខ្លួន ។

–សិស្ស និស្សិត មធ្យមសិក្សាឯកទេស និងបឋមសិក្សាឯកទេស ត្រូវអនុវត្តតាមស្មារតីអនុក្រឹត្យថ្មីនេះ។

ខ–ផ្នែកបណ្តុះបណ្តាលគ្រូបង្រៀនគ្រប់កំរិតសិក្សា ផ្នែកកីឡា និង សៀក ត្រូវបានទទួលអាហារូបករណ៍មួយរយភាគរយ ។

**មាត្រា ៤** : អាទិភាពក្នុងការផ្តល់អាហារូបករណ៍

ការផ្តល់អាហារូបករណ៍ ត្រូវអនុវត្តតាមគោលការណ៍អាទិភាពដូចខាងក្រោម ÷

១– សិស្ស និស្សិត គោរពវិន័យបានល្អ និង រៀនពូកែ

២– កូនកំព្រាឪពុក ម្តាយ និង មានជីវភាពរស់នៅជួបការលំបាកខ្លាំង

៣– កូនជនជាតិភាគតិចនៅតំបន់ដាច់ស្រយាល

៤- កូនកសិករក្រ និង កូនមន្ត្រីរាជការដែលឪពុក ម្តាយមានជីវភាពរស់នៅជួបការលំបាក ។

-ក្នុងអាទិភាពទាំង៤ ខាងលើ នារីភេទត្រូវបានយកចិត្តទុកដាក់មុនគេ ។

មាត្រា ៥ : ការកំណត់ឈ្មោះ សិស្ស និស្សិត ដែលត្រូវបានទទួលអាហារូបករណ៍ និងការពិនិត្យ វាយតំលៃផ្តល់អាទិភាពដូចក្នុងមាត្រា៣ និង មាត្រា ៤ ខាងលើត្រូវធ្វើមួយឆ្នាំម្តងដោយក្រុមប្រឹក្សាវិន័យរបស់សាលា ។

មាត្រា ៦ : ចំពោះមន្ត្រីអ្នករាជការគ្រប់ប្រភេទ ដែលស្ថាប័នមានសមត្ថកិច្ចអនុញ្ញាតអោយទៅចូលរួមសិក្ខាសាលាធ្វើក្រឹតការ សុក្រឹតការ ឬ បំប៉នមុខជំនាញផ្សេងៗ រយៈពេលពីមួយ " ០១ " ថ្ងៃដល់ " ១០ " ថ្ងៃត្រូវទទួលប្រាក់ស្នាក់នៅ និងបេសកកម្មតាមច្បាប់រដ្ឋ ។ រយៈពេលសិក្សាចាប់ ពីដប់មួយ " ១១ " ថ្ងៃរហូតដល់តិចជាងដប់ពីរ " ១២ " ខែ ត្រូវទទួលប្រាក់ឧបត្ថម្ភអន្តេវាសិកចំនួន "២.០០០៛" ក្នុងមួយថ្ងៃ ។ ចំពោះសិក្ខាកាមដែលមានលំនៅដ្ឋាននៅជិតអាចទៅមកស្នាក់នៅផ្ទះ របស់ខ្លួនបានត្រូវទទួលប្រាក់ឧបត្ថម្ភចំនួន " ១.០០០៛ " ក្នុងមួយថ្ងៃ ។

មាត្រា ៧ : សិស្សជនជាតិភាគតិច និង សិស្សមានជីវភាពក្រលំបាកខ្លាំង នៅតំបន់ដាច់ស្រយាល ដែលរដ្ឋបានកំណត់ ហើយដែលមកសិក្សានៅក្នុងអន្តេវាសិកដ្ឋាន នៃអនុវិទ្យាល័យ វិទ្យាល័យ ឬទីប្រជុំជនស្រុក ឃុំ ដែលមានអន្តេវាសិកដ្ឋានត្រូវបានទទួលប្រាក់ឧបត្ថម្ភជីវភាពប្រចាំថ្ងៃម្នាក់ៗចំនួន មួយពាន់ " ១.០០០៛ " រៀល និងរបបឧបត្ថម្ភសំរាប់សំភារៈដំណេក និង សំភារៈសិក្សាប្រចាំឆ្នាំក្នុង ម្នាក់ៗចំនួនប៉ែតសិបពីរម៉ឺនបីរយរៀល "៨០.៣០០៛" រៀល ។

មាត្រា ៨ : ក្រសួងអប់រំយុវជន និងកីឡា មានភារកិច្ចណែនាំអនុវត្តអនុក្រឹត្យនេះ ។ អនុក្រឹត្យសេចក្តីសំរេច និងបទបញ្ញាទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៩ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ គ្រឹះស្ថាន

ឧត្តមសិក្សា និងសិក្សាឯកទេសទាំងអស់ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗ ខ្លួនអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខាតទៅ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខា និង ត្រា ហត្ថលេខា និង ត្រា
**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ១៩៩៧

**អនុក្រឹត្យលេខ : ៤៤ អនក្រ.តត**

**ស្តីពីការជូនមេដាយ ស្ថាបនាជាតិ**

* * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២

**សំរេច**

ប្រការ ១ : ត្រូវបានប្រគល់មេដាយមាស ស្ថាបនាជាតិជូនលោក LIU CHIN MU អគ្គនាយកក្រុមហ៊ុន LAN SONG INTERNATIONAL Co. LTD ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ចំនួន ១០៥.០០០ ដុល្លារ សហរដ្ឋអាមេរិក ដើម្បីចូលរួមជាមួយរាជរដ្ឋាភិបាល ក្នុងការស្តារ និងកសាងប្រទេសជាតិ ។